# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងពាណិជ្ជកម្ម

## កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF)

**ឈ្មោះគម្រោង៖** កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជា ជំហានទី១ (CEDEP)

**រយៈពេលគម្រោង៖** ៣ឆ្នាំ (ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១២ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥)

**ទឹកប្រាក់សរុប (EIF)** ២.៤០៧.៧១៤ ដុល្លារអាមេរិក (មិនបញ្ចូលការចូលរួមឧបត្ថម្ភពីអ្នកគាំទ្រផ្សេងទៀត)

# កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF)

# របាយការណ៍វាយតម្លៃពាក់កណ្តាលគម្រោង

# (ខែតុលា-ខែវិច្ឆិកា ឆ្នាំ២០១៤)


**ក្រុមវាយតម្លៃ៖**

១. Ms. Céline Bacrot ប្រធានទីប្រឹក្សាវាយតម្លៃអន្តរជាតិ

២. Mr. Yim KimChhean ទីប្រឹក្សាវាយតម្លៃថ្នាក់ជាតិ


**កាលបរិច្ឆេទ៖** ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤, រាជធានីភ្នំពេញ កម្ពុជា

# ពាក្យបំប្រួញ

| | |
|---|---|
| AFD | ទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសបារាំង |
| AfD | ជំនួយសម្រាប់ពាណិជ្ជកម្ម |
| ARPEC | សម្ព័ន្ធសហភាពអ្នកផលិតស្រូវអង្ករ និងអ្នកនាំចេញកម្ពុជា |
| CARDI | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CEDEP | កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជា |
| C/O | វិញ្ញាបនបត្របញ្ជាក់ពីប្រភពទំនិញ |
| CREA | សមាគមអ្នកនាំចេញស្រូវអង្ករកម្ពុជា |
| CRF | សហព័ន្ធស្រូវអង្ករកម្ពុជា |
| CTIS | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា |
| DAC | គណៈកម្មការជំនួយការអភិវឌ្ឍន៍ |
| DICO | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| DIPR | នាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| DP | ដៃគូអភិវឌ្ឍន៍ |
| EU | សហគមន៍អឺរ៉ុប |
| EIF | កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម |
| EPWG | ក្រុមការងារជំរុញការនាំចេញ |
| ES | អគ្គលេខាធិការដ្ឋានប្រតិបត្តិ |
| FASMEC | សហព័ន្ធសមាគមសហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា |
| FCRE | សហព័ន្ធអ្នកនាំចេញស្រូវអង្ករកម្ពុជា |
| FGD | ផ្តោតលើកិច្ចពិភាក្សាជាក្រុម |
| G-PSF | កិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងវិស័យឯកជន |
| HACCP | ប្រពន្ធ័វិភាគនិងត្រួតពិនិត្យសុវត្ថភាពចំណីអាហារ |
| HU | មិនអាចទទួលយកបានកម្រិតខ្ពស់ |
| HS | អាចទទួលយកបានកម្រិតខ្ពស់ |
| IC | គណៈកម្មការអនុវត្ត |
| IF | សមាហរណកម្មគម្រោងផែនការ |
| IFC | សាជីវកម្មហិរញ្ញវត្ថុកម្ពុជា |
| IPR | កម្មសិទ្ធិបញ្ញា |
| ITC | មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ |
| ISC | វិទ្យាស្ថានស្តង់ដារកម្ពុជា |

| | |
|---|---|
| KPI | សូចនាករសំខាន់លើកិច្ចប្រតិបត្តិការ |
| LDCs | ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច |
| LO | មន្ត្រីទំនាក់ទំនង |
| Logframe | ផែនការលម្អិត |
| M&E | ការតាមដាន និងវាយតម្លៃ |
| MAFF | ក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ |
| MDTF | មូលនិធិពហុម្ចាស់ជំនួយ |
| MDGs | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIE | អង្គភាពអនុវត្តគម្រោងសំខាន់ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoU | អនុស្សារណៈយោគយល់គ្នា |
| MoIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MoWA | ក្រសួងកិច្ចការនារី |
| MTE | ការវាយតម្លៃពាក់កណ្តាលគម្រោង |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MS | អាចទទួលយកបានកម្រិតមធ្យម |
| NIA | ការរៀបចំការអនុវត្តន៍គម្រោងថ្នាក់ជាតិ |
| NIU | អង្គរភាពអនុវត្តគម្រោងថ្នាក់ជាតិ |
| NSB | គណៈកម្មការសូត្រជាតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិ |
| POC | ចំណាយជាអាទិភាពលើកិច្ចប្រតិបត្តិការ |
| PSC | គណៈកម្មការតម្រង់ទិសកម្មវិធី |
| UNCTAD | អង្គការសហប្រជាជាតិនៃសន្និសិទ្ធលើការអភិវឌ្ឍន៍ និងពាណិជ្ជកម្ម |
| UNDP | អង្គការសហប្រជាជាតិនៃកម្មវិធីអភិវឌ្ឍន៍ |
| UNIDO | អង្គការសហប្រជាជាតិនៃកម្មវិធីអភិវឌ្ឍន៍វិស័យឧស្សាហកម្ម |
| UNOPS | អង្គការសហប្រជាជាតិនៃការិយាល័យ សេវាសម្រាប់គម្រោង |
| VC | ខ្សែសង្វាក់តម្លៃ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RMB | ការគ្រប់គ្រងផ្អែកលើលទ្ធផល |
| RSTWG | ក្រុមការងារបច្ចេកទេសស្តង់ដារអង្ករ |

| | |
|---|---|
| SME | សហគ្រាសខ្នាតូច និងមធ្យម |
| RSSP | គម្រោងគាំទ្រវិស័យស្រូវអង្ករកម្ពុជា |
| SSC.TD-TRI/SSC | អនុគណៈកម្មការតម្រង់ទិសការ អភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគពាក់ព័ន្ធវិស័យពាណិជ្ជកម្ម |
| SPS | អនាម័យ និងភូតគាមអនាម័យ |
| SWAp | អភិក្រមគ្របដណ្តប់លើវិស័យ |
| TA | ជំនួយបច្ចេកទេស |
| TAC-2 | គណៈកម្មការវាយតម្លៃ ជំហានទី២ |
| TBT | របាំងបច្ចេកទេសពាណិជ្ជកម្ម |
| TDSP | កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម |
| TFM | ប្រធានគ្រប់គ្រងមូលនិធិអាណត្តិ |
| ToR | លក្ខខណ្ឌការងារ |
| TPR | ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម |
| TRTA | ជំនួយបច្ចេកទេសដែលពាក់ព័ន្ធវិស័យពាណិជ្ជកម្ម |
| TWG | ក្រុមការងារបច្ចេកទេស |
| WB | ធនាគារពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

## សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងសម្របសម្រួលការប្រើប្រាស់ និងអនុវត្តនៃជំនួយពាណិជ្ជកម្ម។ អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) មានសសរស្តម្ភបី ជាយុទ្ធសាស្ត្រសំខាន់។ សសរស្តម្ភទី២ ផ្តោតទៅលើការពង្រឹងសមត្ថភាពផ្គត់ផ្គង់ការនាំចេញលើវិស័យសំខាន់ៗចំនួន ១៩។

តាមរយៈគម្រោងនេះ កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជា ជំហានទី១ (CEDEP I) ដែលផ្តល់មូលនិធិដោយ កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) របស់ Trust Fund មានគោលបំណងធ្វើការពង្រឹង និងធ្វើពិពិធកម្មសមត្ថភាពផ្គត់ផ្គង់ការនាំចេញដោយជ្រើសរើសវិស័យ សំខាន់ៗពីសសរស្តម្ភទី២ គឺវិស័យសូត្រប្រណិត និងវិស័យអង្ករ។ កម្មវិធីនោះក៏បានដាក់បញ្ចូលនូវសមាសភាគមុខងារវាយតម្លៃ ដែលបានកំណត់ដើម្បីពង្រឹងសមត្ថភាពរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) នៃក្រសួងពាណិជ្ជកម្ម (MOC) ក្នុងការតាមដាន និងវាយតម្លៃឯករាជ្យភាព វឌ្ឍនភាពរបស់ Trade SWAp ។ កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់ កម្ពុជាជំហានទី១ (CEDEP I) ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់កម្មវិធីពង្រឹងក្របខណ្ឌសមហរណកម្ម (EFI) នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១២ ។

គោលបំណងក្នុងការវាយតម្លៃពាក់កណ្តាលគម្រោងគឺ **"ពិនិត្យឡើងវិញការអនុវត្តន៍គម្រោងដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែទូលំទូលាយនូវការអនុវត្តន៍គម្រោង CEDEP I ដើម្បីឲ្យការគ្រប់គ្រង គម្រោង មានប្រសិទ្ធភាព និងផលិតផលខ្ពស់។ ការវាយតម្លៃពាក់កណ្តាលគម្រោងក៏ចូលរួមចំណែកក្នុងការកំណត់បាននូវឧបសគ្គលើកិច្ចប្រតិបត្តិការ ផ្តល់ជាយុត្តិកម្មក្នុងការអនុវត្តន៍គម្រោងដំណាក់កាលទី២ (២០១៤-២០១៦) និងផ្តល់ជាព័ត៌មានដល់កម្មវិធីជាសកលនៃកម្រិតវាយតម្លៃរបស់ EIF"** ។

ក្រុមការងារវាយតម្លៃ មាន **Ms. Celine Bacrot** ជាទីប្រឹក្សាអន្តរជាតិនាំមុខវាយតម្លៃ និង **Yim KimChhean** ទីប្រឹក្សាជាតិផ្នែកវាយតម្លៃ ។

ការវាយតម្លៃ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៤ ដល់ថ្ងៃទី ៣១ ខែតុលាឆ្នាំ២០១៤។ ការវាយតម្លៃនេះក៏បានដាក់បញ្ចូលនូវការធ្វើដំណើរទៅកាន់គោលដៅផ្សេងៗរបស់គម្រោងផងដែរ។

វិសាលភាពនៃការវាយតម្លៃរបស់គម្រោងគ្របដណ្តប់លើចំណុចសំខាន់ៗ៣ គឺប្រតិបត្តិការនៃគម្រោង លទ្ធផលដែលសម្រេចបាននៅពាក់កណ្តាលគម្រោង និងអនុសាសន៍សម្រាប់ដំណាក់កាលបន្ទាប់។

ការវាយតម្លៃត្រូវបានយោងទៅលើលក្ខណៈវិនិច្ឆ័យរបស់ OECD ក្នុងការវាស់វែងការសម្រេចបានរបស់គម្រោង៖ **ទំនាក់ទំនង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តភាព និងសក្តានុពលនៃផលប៉ះពាល់** ។

## ការវាយតម្លៃលើការអនុវត្តគម្រោង

កិច្ចប្រតិបត្តិការរបស់ CEDEP I ត្រូវបានអនុវត្តដោយភ្នាក់ងារសំខាន់ៗចំនួន៣ ដោយបានចុះហត្ថាលេខាលើអនុស្សារណៈនៃការយោគយល់ (MOU) ដាច់ដោយឡែកពីគ្នាជាមួយ ប្រធានគ្រប់គ្រង EIF Trust Fund ដូចខាងក្រោម៖

- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC/The World Bank Group) ទទួលខុសត្រូវលើកិច្ចប្រតិបត្តិការសមាសភាគនាំចេញអង្ករ។ ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ (MOU) ធ្វើនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១២។
- មជ្ឈមណ្ឌល ពាណិជ្ជកម្មអន្តរជាតិ (ITC) (UNCTAD/WTO) ទទួលខុសត្រូវលើកិច្ចប្រតិបត្តិការសមាសភាគនាំចេញសូត្រប្រណិត។ ពិធីចុះហត្ថលេខាលើអនុ ស្សារណៈនៃការយោគយល់ (MOU) ធ្វើនៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២។
- The MoC/DICO ទទួលខុសត្រូវលើសមាសភាគមុខងារវាយតម្លៃ។ ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ (MOU) ធ្វើនៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ និងបំពេញបន្ថែមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤។

កម្រិតនៃកិច្ចប្រតិបត្តិការ ពឹងផ្អែកទាំងស្រុងទៅលើធាតុដើមសកម្មភាពផ្សេងៗ។ សកម្មភាពផលិតផល និងការអភិវឌ្ឍទីផ្សារ ត្រូវបានបញ្ចប់ ឬបន្ត ខណៈពេលដែលសកម្មភាព ពាក់ព័ន្ធនឹងបរិវេណវិទ្យាស្ថានបណ្តុះបណ្តាល ត្រូវបានពន្យាពេល ឬមិនទាន់ចាប់ផ្តើមនៅឡើយ ប៉ះពាល់ដល់សមិទ្ធិផលរបស់គម្រោងនេះ។ ខាងក្រោមនេះជាស្ថានការណ៍នៃការអនុវត្តន៍របស់សមាសភាគទាំងបីតាមរយៈលទ្ធផល និងទិន្នផល ៖

**សមាសភាគទី១ ការនាំចេញអង្ករ**

| សកម្មភាព | ស្ថានការណ៍ ៣០ មិថុនា ឆ្នាំ២០១៤ |
|---|---|
| **លទ្ធផលទី១៖** ការបង្កើនបរិយាសកាសដល់វិស័យឯកជនកម្ពុជា ក្នុងការសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការនាំចេញស្រូវអង្ករ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង និងមាននិរន្តភាពតាមរយៈការបង្កើតសមាគមនាំចេញអង្ករ និងពង្រឹងកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងវិស័យឯកជនស្តីអំពីអង្ករ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ឬក្នុងកន្លែងផ្សេងៗទៀត។ | **បញ្ចប់** |
| ទិន្នផលទី១៖ ក្រុមការងារបច្ចេកទេសត្រូវបានរៀបចំឡើងរវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញ សម្រាប់ការរៀបចំជាសមាគម។ | បញ្ចប់ |
| ទិន្នផលទី២៖ ធ្វើបច្ចុប្បន្នភាពផែនទីខ្សែសង្វាក់តម្លៃស្រូវអង្ករ (ផ្អែកលើផែនទីគោលនយោបាយអង្ករ) (នឹងត្រូវបញ្ចប់ដោយរួមបញ្ចូលខ្សែសង្វាក់តម្លៃរបស់ក្រសួងពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធផ្សេងៗទៀត) | កំពុងបន្ត |
| ទិន្នផលទី៣៖ មុខងាររបស់សមាគម ត្រូវបានបង្កើត និងចុះឈ្មោះ | បញ្ចប់ |
| ទិន្នផលទី៤៖ យន្តការពិគ្រោះយោបល់ជាទៀងទាត់រវាងរាជរដ្ឋាភិបាល និងអ្នកនាំចេញអង្ករ ស្តីពីការនាំចេញត្រូវបានបង្កើតតាមរយៈវេទិកាពិគ្រោះយោបល់រាជរដ្ឋាភិបាល និងវិស័យឯកជន (G-PSF) ឬកម្មវិធីផ្សេងៗ ទៀត។ | បញ្ចប់ |

| | |
|---|---|
| **លទ្ធផលទី២៖** រោងម៉ាស៊ីនកិនស្រូវកម្ពុជាទទួលបានជោគជ័យក្នុងការកំណត់បាននូវឱកាសទីផ្សារនាំចូលធំៗថ្មីមួយចំនួន (បន្ថែមទៅលើ ទីផ្សារ សហគមន៍អឺរ៉ុប និង រុស្ស៊ី)។ | **កំពុងបន្ត** |
| ទិន្នផលទី១៖ វិភាគសក្តានុពលទីផ្សារ / បង្កើតព័ត៌មានពាណិជ្ជកម្មសម្រាប់ទីផ្សារថ្មីចំនួន៥ (និងបញ្ចប់ដោយរួមបញ្ចូលខ្សែសង្វាក់តម្លៃរបស់ក្រសួងពាណិជ្ជកម្ម)។ | កំពុងបន្ត |
| ទិន្នផលទី២៖ សៀវភៅណែនាំស្តីនិតិវិធីការនាំចេញ / សម្របសម្រួលពាណិជ្ជកម្ម ត្រូវបានចេញផ្សាយ ។ | កំពុងបន្ត |
| ទិន្នផលទី៣៖ សៀវភៅណែនាំស្តីពីនិតិវិធីស្តង់ដារអនាម័យ និងភូតគាមអនាម័យ និងតម្រូវការវិញ្ញាបនបត្រសម្រាប់ផលិតផលស្រូវអង្ករ ត្រូវបានចេញផ្សាយ។ | កំពុងបន្ត |
| ទិន្នផលទី៤៖ រៀបចំនិងបោះពុម្ពផ្សាយសន្លឹកបត្របញ្ជីអង្ករកម្ពុជា | បញ្ចប់ |
| ទិន្នផលទី៥៖ ក្រុមការងារនៃរោងម៉ាស៊ីនកិនស្រូវដែលបាននាំចេញ និងកំពុងនាំចេញ បានចុះពិនិត្យមើលទីផ្សារសក្តានុពលចំនួនបី។ | កំពុងបន្ត |
| ទិន្នផលទី៦៖ រោងម៉ាស៊ីនកិនស្រូវដែលបាននាំចេញ និងកំពុងនាំចេញ បានចូលរួមពិពណ៌សំខាន់ៗចំនួន៤ ស្តីពីពាណិជ្ជកម្មស្រូវអង្ករ សំខាន់ៗចំនួន ៤ និងចូលរួមជំនួបរវាងអ្នកទិញ និងអ្នកលក់ (ពេលវេលាពិតប្រាកដអាស្រ័យលើតារាងពេលវេលា)។ | បញ្ចប់ |
| ទិន្នផលទី៧៖ រោងម៉ាស៊ីនកិនស្រូវចំនួន៨ និងទទួលបានវិញ្ញាបនបត្របញ្ជាក់ HACCP ដោយមានជំនួយគាំទ្រពីគម្រោង។ | កំពុងបន្ត |
| **លទ្ធផលទី៣៖** អង្ករកម្ពុជាទទួលបានភាពជោគជ័យដោយទទួលបានកិច្ចសន្យានាំចេញដែលបំពេញបានទាំងបរិមាណ គុណភាព និងតម្លៃដែលអ្នកនាំចូលស្នើ ជាពិសេសគឺអង្ករក្រអូបដែលត្រូវបានផលិតឡើងជាម៉ាកផលិតផលឈានមុខគេរបស់អង្ករកម្ពុជា។ | **កំពុងបន្ត** |
| ទិន្នផលទី១៖ បង្កើតម៉ាកផលិតផលអង្ករក្រអូបកម្ពុជា ជាប្រភេទអង្ករក្រអូបដែលមានគុណភាពសម្រាប់នាំចេញ ដែលអាចប្រកួតប្រជែងជាមួយអង្ករក្រអូបថៃ និងអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។ | កំពុងបន្ត |
| ទិន្នផលទី២៖ ជម្រុញម៉ាកផលិតផលអង្ករក្រអូបកម្ពុជា។ | កំពុងបន្ត |

## សមាសភាគទី២ ការនាំចេញសូត្រប្រណិត

| សកម្មភាព | ស្ថានការណ៍<br>៣១ កក្កដា ឆ្នាំ២០១៤ |
|---|---|
| **លទ្ធផលទី១៖** ការអភិវឌ្ឍន៍ទីផ្សារ | **បញ្ចប់** |
| ទិន្នផលទី១.១៖កំណត់សក្តានុពលនាំចេញ និងកំណត់ទីផ្សារគោលដៅសំខាន់ៗ សម្រាប់ផលិតផលសូត្រប្រណិត។ | បញ្ចប់ |
| ទិន្នផលទី១.២៖ ពង្រឹងសមត្ថភាពទីផ្សារដល់អ្នកនាំចេញដែលបានជ្រើសរើស និងលម្អិតយុទ្ធសាស្ត្រទីផ្សារនាំចេញ។ | បញ្ចប់ |
| ទិន្នផលទី១.៣៖ អ្នកនាំចេញធ្វើការស្រាវជ្រាវទីផ្សារបរទេសយ៉ាងសកម្ម | កំពុងបន្ត |
| **លទ្ធផលទី២៖** ការអភិវឌ្ឍន៍ផលិតផល | **បញ្ចប់** |
| ទិន្នផលទី២.១៖ ពង្រឹងជំនាញរបស់អ្នកនាំចេញជាបុរស និងស្ត្រីក្នុងការច្នៃប្រឌិត និងរចនាផលិតផល | បញ្ចប់ |
| ទិន្នផលទី២.២៖ ការធ្វើសមាហរណកម្មបញ្ចូល នៃខ្សែសង្វាក់តម្លៃរបស់សូត្រ និងបង្កើនជំនាញបច្ចេកទេសដល់សហគមន៍តម្បាញដើម្បីបង្កើតផលិតកម្ម ផលិតផលសូត្រប្រណិតក្នុងបរិមាណច្រើន។ | កំពុងបន្ត |
| ទិន្នផលទី២.៣៖ ការនាំចូលអំបោះសូត្រ គឺអាចធានាបានទាំង គុណភាព និង ការត្រួតពិនិត្យ ។ | បញ្ចប់ |
| **លទ្ធផលទី៣៖** ការសម្របសម្រួលលើវិស័យសូត្រ និងយុទ្ធសាស្ត្រ | **មិនទាន់បញ្ចប់** |
| ទិន្នផលទី៣.១៖ គណកម្មការ និងលេខាធិការដ្ឋានលើវិស័យសូត្រត្រូវបានបង្កើត។ ក្រុមការងារនៃគ្រប់ភាគីពាក់ព័ន្ធត្រូវបានបង្កើតទៅតាមបញ្ហាគន្លឹះសំខាន់ៗក្នុងរៀបចំវិស័យសូត្រ ។ | កំពុងបន្ត |
| ទិន្នផលទី៣.២៖ យែនឌ័រត្រូវបានពិចារណាឲ្យដាក់បញ្ចូលក្នុងផែនការសកម្មភាព និងយុទ្ធសាស្ត្រវិស័យសូត្រ ដើម្បីអភិវឌ្ឍន៍ជាមួយភាគីពាក់ព័ន្ធ។ | មិនទាន់បញ្ចប់ |
| ទិន្នផលទី៣.៣៖ ប្រសិទ្ធភាពគ្រប់គ្រងការអនុវត្តន៍ និងតាមដានត្រូវបានបង្កើត | មិនទាន់បញ្ចប់ |

**សមាសភាគទី៣ មុខងារវាយតម្លៃ និងការរៀបចំមន្ត្រីការងារស្នូល**

| សកម្មភាព | ស្ថានការណ៍ ៣១ កញ្ញា ឆ្នាំ២០១៤ |
|---|---|
| **លទ្ធផលទី១៖** ពង្រឹងសមត្ថភាពអង្គភាពអនុវត្តថ្នាក់ជាតិ *(NIU)* ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាពដែលបានអនុវត្តក្រោម Trade SWAp ដោយរួមបញ្ចូលការវាយតម្លៃផលប៉ះពាល់ និងលទ្ធផលនៃជំនួយបច្ចេកទេស។ | **មិនទាន់បញ្ចប់** |
| ទិន្នផលទី១៖ ការវាយតម្លៃពាក់កណ្ដាលគម្រោងដោយឯករាជ្យ នៃដំណាក់កាលទី២ (Tier 2) របស់គម្រោង ត្រូវបានរៀបចំ និងអនុវត្ត។ | បញ្ចប់ |
| ទិន្នផលទី២៖ ការវាយតម្លៃបញ្ចប់គម្រោងដោយឯករាជ្យនៃដំណាក់កាលទី២ (Tier 2) របស់គម្រោង ត្រូវបានរៀបចំ និងអនុវត្ត។ | មិនទាន់បញ្ចប់ |
| **លទ្ធផលទី២៖** ពង្រឹងសមត្ថភាពរបស់អង្គភាពអនុវត្តថ្នាក់ជាតិដើម្បីផ្សព្វផ្សាយវឌ្ឍនភាព និងលទ្ធផលជំនួយបច្ចេកទេសដែលបានអនុវត្តក្រោម Trade SWAp | **មិនទាន់បញ្ចប់** |
| ទិន្នផលទី១៖ លទ្ធផលរបស់គម្រោង និងផលប៉ះពាល់ត្រូវបានបកស្រាយ និងផ្សព្វផ្សាយមួយឆ្នាំម្ដងតាមរយៈសិក្ខាសាលាថ្នាក់តំបន់ចំនួន៥។ | មិនទាន់បញ្ចប់ |
| ទិន្នផលទី២៖ ការរកឃើញដែលទទួលបានតាមរយៈការវាយតម្លៃ (ពាក់កណ្ដាល និងបញ្ចប់) ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា និងទៅកាន់សហគមន៍អន្តរជាតិ។ | មិនទាន់បញ្ចប់ |

## ការរកឃើញរបស់គម្រោងផ្អែកលើលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ

### ទំនាក់ទំនង

គោលបំណងទាំងមូលនៃគម្រោង CEDEP I គឺដើម្បីពង្រឹង និងពិពិធកម្មសមត្ថភាពផ្គត់ផ្គង់ការនាំចេញលើវិស័យអង្ករ និងសូត្រប្រណិត និងបង្កើនសមត្ថភាពដល់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិរបស់ក្រសួងពាណិជ្ជកម្មក្នុងការតាមដាន និងវាយតម្លៃពីវឌ្ឍនភាពសំខាន់ៗរបស់អភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្មរបស់កម្ពុជា (Trade SWAp)។ ដូចបានចែងនៅក្នុងឯកសារ គម្រោង CEDEP I[1] "សមាសភាគនៃវិស័យទាំងពីរ និងត្រូវបានផ្ដោតជាសំខាន់លើ**កំណើនការនាំចេញតាមរយៈការធ្វើពិពិធកម្ម** ដោយរួមបញ្ចូលការអភិវឌ្ឍន៍ផលិតផល និងសេវាដែលធ្វើអោយ**សង្វាក់តម្លៃនៃវិស័យទាំងនេះកើនឡើង** និង**អាចវាយលុកទីផ្សារនាំចូលថ្មី**។"

សមាសភាគទាំងបីរបស់ CEDEP I គឺមានទំនាក់ទំនងទៅនឹងគោលដៅរបស់គម្រោងដែលសកម្មភាពក្របខ័ណ្ឌ និងឯកសារគម្រោងគឺផ្ដោតទៅលើការពង្រឹងសមត្ថភាពផ្គត់ផ្គង់របស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញសូត្រ និងបង្កើតឱ្យមានស្ថាប័ននៅតាមផ្នែកនីមួយៗក្នុងគោលបំណងនាំចេញអង្ករ

[1] ឯកសារគម្រោង EIF CEDEP I, ទំព័រ ៧

និងសូត្រប្រណិតទៅកាន់ទីផ្សារនាំចូលថ្មីៗ និងជំរុញសមត្ថភាពវាយតម្លៃរបស់ Moc/DICO។ ក្នុងលក្ខណខណ្ឌនៃទំនាក់ទំនង គម្រោងនេះត្រូវបានចាត់ទុកថា **អាចទទួលយកបានកម្រិតខ្ពស់** ។

## ប្រសិទ្ធផល

គម្រោងនេះអាចចាត់ទុកថាមានប្រសិទ្ធផលចំពោះលទ្ធផលមួយចំនួន នៃសមាសភាគនីមួយៗ (លទ្ធផលទី២ និងទី៣ នៃសមាសភាគទី១ និងលទ្ធផលទី១ និងទី២ នៃសមាសភាគទី២)។ ក៏ប៉ុន្តែ គម្រោងទាំងមូលមិនអាចកំណត់ថាមានប្រសិទ្ធផលបានទេ ដោយសារសកម្មភាពមួយចំនួនមិនអាចសម្រេចបានទៅតាមតារាងពេលវេលានៃការអនុវត្តគម្រោង។

ការពន្យារពេលនៃការបង្កើតគណកម្មការសូត្រជាតិ បានក្លាយជាបញ្ហាចំបងក្នុងការអនុវត្តន៍សកម្មភាពផ្សេងៗទៀតដែលនៅសល់ក្នុងលទ្ធផលទី៣ នៃសមាសភាគសូត្រប្រណិត ដូចជាការរៀបចំយុទ្ធសាស្រ្តថ្នាក់ជាតិលើវិស័យសូត្រ។ ការពន្យារពេលនេះបានបង្កឱ្យមានកង្វះខាតចក្ខុវិស័យ និងផែនការរយៈពេលវែងលើវិស័យសូត្រ។ ស្ថាប័នដែលទើបបង្កើតថ្មី គឺសហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានរួមចំណែកពន្យារពេលដល់ការអនុវត្តន៍សកម្មភាពមួយចំនួននៅក្នុងលទ្ធផលទី១ នៃសមាសភាគអង្ករ ក្នុងការសម្របសម្រួលលើអភិបាលកិច្ចវិស័យស្រូវអង្ករ និងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធផលប៉ះពាល់មួយចំនួន (គ្រាប់ពូជ ដើមទុន ។ល។)។ សហព័ន្ធស្រូវអង្ករកម្ពុជា នៅមានតម្រូវការក្នុងការពង្រឹងសមត្ថភាពមួយចំនួនដើម្បីអាចឱ្យសហព័ន្ធធ្វើប្រតិបត្តិការបានពេញលេញ និងឆ្លើយតបទៅនឹងតម្រូវការសំខាន់ក្នុងវិស័យនេះ។ សមាសភាគទី៣ ស្តីពីមុខងារវាយតម្លៃ ត្រូវការរយៈពេលយូរជាងការរំពឹងទុកដើម្បីចាប់ផ្តើមអនុវត្តដោយសារការផ្លាស់ប្តូរចនាសម្ព័ន្ធប្រតិបត្តិការរបស់សមាសភាគ។ ការពន្យារពេលបានធ្វើឱ្យប៉ះពាល់ដល់ការធ្វើប្រតិបត្តិការរបស់មន្ត្រីក្រុមស្នូល និងយន្តការលុបបំបាត់ចំណាយជាអាទិភាពលើប្រតិបត្តិការ (POC) ដែលនាំអោយមានការកែសម្រួលអនុស្សារណៈ (MoU) រវាង TFM និងក្រសួងពាណិជ្ជកម្មស្តីពីមុខងារវាយតម្លៃ នៅក្នុងខែសីហា ឆ្នាំ២០១៤។ កត្តាទាំងអស់នេះ បានធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធផលនៃសមាសភាគ ក្នុងការតាមដាននិងវាយតម្លៃពីវឌ្ឍនភាព និងលទ្ធផលសម្រេចបានរបស់សមាសភាគពីរផ្សេងៗទៀត។

ជាចុងក្រោយ ព័ត៌មានសង្ខេបស្តីពីហិរញ្ញវត្ថុបានបង្ហាញពីភាពមិនស៊ីសង្វាក់គ្នានៃអត្រាប្រាក់ចំណាយដែលឆ្លុះបញ្ចាំងពីប្រតិបត្តិការរបស់សមាសភាគនីមួយៗ។ IFC មានអត្រាប្រាក់ចំណាយ ៥៨% ITC មានអត្រាប្រាក់ចំណាយ ៨៥% និងសមាសភាគទី៣ របស់ MoC/DICO មានអត្រាប្រាក់ចំណាយ ២,២៥%[2]។

សរុបសេចក្តីមក គម្រោងទាំងមូលមិនអាចចាត់ទុកថាមានប្រសិទ្ធផលនោះទេ ពីព្រោះនៅពេលបញ្ចប់គម្រោងសកម្មភាពមួយចំនួនមិនអាចអនុវត្តបាន ។ ប៉ុន្តែក៏មានសកម្មភាពមួយចំនួនត្រូវបានអនុវត្តនិងបញ្ចប់ទៅតាមតារាងពេលវេលានៃការអនុវត្តន៍គម្រោង។ គម្រោងនេះអាចទុកថា **អាចទទួលយកបាន** ដោយផ្អែកលើប្រសិទ្ធផល។

## ប្រសិទ្ធភាព

[2] មើលឧបសម្ព័ន្ធទី៥

គម្រោងនេះសម្រេចបានលទ្ធផលល្អប្រសើរ ដែលស្ថិតក្រោមលទ្ធផលដែលពាក់ព័ន្ធទៅនឹងទីផ្សារនាំចេញ និងការអភិវឌ្ឍន៍ផលិតផលនៃសមាសភាគទី១ និងទី២។ នៅក្រោមសមាសភាគអង្ករវឌ្ឍនភាពដែលសម្រេចបាន បានឈានទៅតាមគោលដៅទាំងពីរ គឺការនាំចេញអង្ករថ្នាក់ជាតិ និងកិច្ចព្រមព្រៀងនាំចេញដែលទទួលបានតាមរយៈគម្រោង។ កិច្ចព្រមព្រៀងបរិមាណនាំចេញអង្ករដែលបានសម្របសម្រួលគឺ ៦៦,៤៩០តោន ធៀបគោលដៅសរុប៨១,០០០តោន និងកិច្ចព្រមព្រៀងតម្លៃនាំចេញអង្ករ ដែលបានសន្និដ្ឋាន និងសម្របសម្រួលដោយ IFC មានទំហំទឹកប្រាក់ ៤៣,៤១១,៣៣៥ ដុល្លារអាមេរិក ក្នុងនោះ ៥០% ជាកិច្ចព្រមព្រៀងនាំចេញអង្ករក្រអូប ធៀបគោលដៅសរុប ៤៨,៧៦២,០០០ ដុល្លារអាមេរិក។ នៅក្រោមសមាសភាគសូត្រប្រណិត មានការកើនឡើងនៃកំណើនប្រាក់ចំណេញពី ២០-៣០% របស់អ្នកនាំចេញផលិតផលសូត្រសម្រេចក្នុងពេលវាយតម្លៃពាក់កណ្តាលគម្រោង (MTE)។ ការចូលរួមព្រឹត្តការណ៍អន្តរជាតិ និងវគ្គបណ្តុះបណ្តាលបានបង្កើនការទទួលស្គាល់គុណភាពសូត្រកម្ពុជា ដែលឈានទៅដល់ការចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនអន្តរជាតិជាច្រើនក្នុងទីផ្សារនាំចូលថ្មី។

ក៏ប៉ុន្តែសកម្មភាពទាំងឡាយនៃប្រតិបត្តិការដែលពាក់ព័ន្ធទៅនឹងស្ថាប័នបណ្តុះបណ្តាលនៅក្នុងវិស័យទាំងពីរ អង្ករ និងសូត្រ រួមជាមួយសមាសភាគទី៣ ស្តីពីមុខងារវាយតម្លៃ និងការរៀបចំមន្ត្រីទំនាក់ទំនង គឺមិនទាន់មានប្រសិទ្ធភាព និងសកម្មភាពស្ទើរតែទាំងអស់នឹងត្រូវយកទៅអនុវត្តនៅជំហានបន្ទាប់របស់គម្រោងដើម្បីសម្រេចបានលទ្ធផលតាមការរំពឹងទុក។ ការសម្រេចបានគោលដៅ និងលទ្ធផលនៃគម្រោងត្រូវបានចាត់ថា **អាចទទួលយកបាន**។

## សក្តានុពលនៃផលប៉ះពាល់រយៈពេលមធ្យម និងវែង

ការរំពឹងទុកនៃផលប៉ះពាល់របស់គម្រោងរយៈពេលមធ្យម និងវែង ជាពិសេសការអនុវត្តន៍នៅក្នុងសមាសភាគទី១ និងទី២ ក្នុងលក្ខខណ្ឌកាត់បន្ថយភាពក្រីក្រ និងបង្កើតការងារ ប៉ុន្តែក៏ជាការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រទេសលើបញ្ហាប្រឈមពីខាងក្រៅដែលអាចកើតមាននាពេលខាងមុខ។ ទាំងអស់នេះ គឺស្របទៅតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ប្រទេសកម្ពុជា និងគោលបំណងទី១ ទី២ និងទី៣ របស់ Trade SWAp ដែលបានរៀបចំនៅក្នុងផែនទីបង្ហាញផ្លូវសេសរស្តម្ភរបស់ Trade SWAp។ យោងតាមលក្ខណៈវិនិច្ឆ័យលើប្រសិទ្ធភាព លទ្ធផលគោលដៅដែលសម្រេចបានផ្អែកលើផលិតផល និងការអភិវឌ្ឍន៍ទីផ្សារ គឺសំដៅទៅដល់ការកើនឡើងបរិមាណនាំចេញ និងការកើនឡើងប្រាក់ចំណូល។ សរុបសេចក្តីមក គម្រោងនេះអាចចាត់ទុកថាមានផលប៉ះពាល់ជាវិជ្ជមានលើវិស័យទាំងពីរ។

ផែនការលម្អិត (logframe) ត្រូវបានរៀបចំ និងផ្តោតទៅលើសូចនាករពាណិជ្ជកម្ម ដោយមិនបានផ្តោតលើសូចនាករនៃការអភិវឌ្ឍន៍ធនធានមនុស្ស ដែលមិនអាចឱ្យវាយតម្លៃបានទៅលើផលប៉ះពាល់នៃការបន្ថយភាពក្រីក្រ និងការបង្កើតការងារជាពិសេសភាពងាយរងគ្រោះនៃសេដ្ឋកិច្ចរបស់ប្រទេស។ គោលដៅសូចនាករសំខាន់ៗនៃកិច្ចប្រតិបត្តិការ (KPIs) គួរត្រូវបានកំណត់ឱ្យបានច្បាស់លាស់ក្នុងដំណាក់កាលរៀបចំគម្រោងដើម្បីដាក់បញ្ចូលគោលដៅទាំងអស់នេះ។

ផលប៉ះពាល់ស្តីពីកិច្ចសន្ទនារបស់រាជរដ្ឋាភិបាល និងវិស័យឯកជន និងការបង្កើតឡើងនូវស្ថាប័នក្នុងការជំរុញសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការតាមដាន និងឈានទៅដល់ការអនុវត្តន៍លើភាពអំណោយផលនៃបរិយាសកាសវិនិយោគ គឺតម្រូវឱ្យមានការបង្ហាញឱ្យបានច្បាស់លាស់ចំពោះពេលវេលា

ដែលនៅសល់របស់គម្រោង ពីព្រោះការងារពាក់ព័ន្ធមួយចំនួនមិនទាន់ត្រូវបាន អនុវត្តឡើយ។ គម្រោងនេះត្រូវបានចាត់ទុកថា **អាចទទួលយកបាន** ដោយផ្អែកលើសក្ខានុពលនៃផលប៉ះពាល់។

## និរន្តភាព

និរន្តភាពនឹងអាចបំពេញលុះត្រាតែរាល់លក្ខខណ្ឌក្នុងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ត្រូវបានយកមកអនុវត្ត។ ជាការពិតប្រតិបត្តិការពាណិជ្ជកម្មនឹងមាននិរន្តភាពនៅពេលដែលស្ថាប័នពាក់ព័ន្ធសមស្រប ត្រូវបានបង្កើតដើម្បីសម្របសម្រួលបរិយាកាសពាណិជ្ជកម្ម និងលើកទឹកចិត្តដល់ការវិនិយោគតាមរយៈការអនុវត្តន៍គោលនយោបាយ និងបទបញ្ញត្តិបានត្រឹមត្រូវ។

CEDEP I មានគោលបំណងចូលរួមចំណែក ក្នុងកិច្ចប្រតិបត្តិការសម្រាប់គោលដៅរយៈពេលវែង ដែលបានប្រកាសនៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី កិច្ចប្រជុំពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាឡើងវិញ ឆ្នាំ២០១១ (TPR) "កម្ពុជាបានសម្រេចបាននូវការប្រឈមទាំងឡាយដែលបង្កឡើងដោយវិបត្តិសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០០៨-២០០៩។ តាមរយៈហេតុការណ៍នៅក្នុង ឆ្នាំ២០០៨ កម្ពុជាបានបង្ហាញឲ្យឃើញនូវបញ្ហាប្រឈមពីខាងក្រៅផងដែរ [...] ។ នៅក្នុងរយៈពេលខាងមុខ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំប្រឹងប្រែង ពង្រីកការធ្វើសមាហរណកម្មរបស់ខ្លួន ចូលទៅក្នុងប្រព័ន្ធពាណិជ្ជកម្ម ថ្នាក់តំបន់ និងពិភពលោក។ ស្របពេលជាមួយគ្នានេះដែរ ត្រូវកាត់បន្ថយបញ្ហាប្រឈម ផ្នែកសេដ្ឋកិច្ច ដែលកើតមានតាមរយៈប្រព័ន្ធនេះ។ **ការធ្វើពិពិធកម្ម ផលិតផលនាំចេញ និងទីផ្សារនាំចេញ គឺជាកត្តាសំខាន់ដើម្បីសម្រេចបានគោលដៅ។**"[3]

គម្រោងនេះមិនទាន់មាននិរន្តភាពដូចដែលបានរំពឹងទុកឡើយ គឺផ្ទុយពីគោលដៅរយៈពេលវែង។ អវត្តមាននៃស្ថាប័នគ្រប់គ្រងលើវិស័យសូត្រ និងសមត្ថភាពខ្សោយក្នុងការសម្របសម្រួល និងដឹកនាំក្នុងវិស័យអង្ករ បានធ្វើឱ្យប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចសម្រាប់គោលបំណងរយៈពេលវែងថ្នាក់ជាតិ។

នៅក្នុងការងារគម្រោងក៏កំពុងស្ថិតក្នុងហានិភ័យផងដែរ ចំពោះនិរន្តភាពនៃស្ថាប័នរបស់ សមាសភាគនីមួយៗ ដោយសារលទ្ធផលដែលសម្រេចបាននឹងមិនមានស្ថេរភាព ប្រសិនបើគម្រោងការងាររបស់ស្ថាប័នមិនបានចូលរួមចំណែកដល់ដំណើរការរយៈពេលវែង។ ជាការពិត លទ្ធផលទាំងនេះ គួរត្រូវបានបែកចែកទៅតាមវិស័យនីមួយៗ និងបង្កើនការអភិវឌ្ឍន៍ និងវិនិយោគតាមរយៈយុទ្ធសាស្ត្រចូលរួម និងការបង្កបរិយាកាសដល់ការធ្វើពាណិជ្ជកម្ម។ គម្រោងនេះបានកំណត់គោលដៅអ្នកទទួលផលជាតំណាងឱ្យផ្នែកតូចមួយនៃវិស័យនេះ ដោយឡែកចំពោះសមាសភាគសូត្រប្រណិត គឺកំពុងធ្វើការជាមួយអ្នកទទួលផលតែចំនួន ១៩ក្រុមហ៊ុនប៉ុណ្ណោះ។ នៅក្នុងប្រទេសកម្ពុជា ឧស្សាហកម្មតម្បាញសូត្របានផ្តល់ការងារដល់កម្មកររហូតដល់ ២០,០០០នាក់ ដែលភាគច្រើនជាស្ត្រី។ ហេតុដូច្នេះដើម្បីផ្សព្វផ្សាយពីវឌ្ឍនភាពដែលសម្រេចបានរបស់គម្រោងចំពោះវិស័យនេះ បទបញ្ញត្តិការងារគម្រោង គឺតម្រូវឱ្យដាក់ចុះនូវយុទ្ធសាស្ត្រ Top-Down ដែលអ្នកនាំចេញសូត្រគួរចូលរួមចំណែកការអភិវឌ្ឍន៍សហគមន៍ដើម្បីពង្រឹងសង្វាក់តម្លៃនៃវិស័យសូត្រប្រណិត ITC បានចាប់ផ្តើមអនុវត្តសកម្មភាពនានានិងផ្សព្វផ្សាយអត្ថប្រយោជន៍របស់គម្រោងដល់អ្នកនាំចេញសូត្រ ១៩ក្រុមហ៊ុន ក្នុងគោលបំណងដាក់បញ្ចូលទៅក្នុងវិស័យទាំងមូល។

សម្រាប់សមាសភាគអង្ករ គឺទទួលបានលទ្ធផលជាវិជ្ជមាននឹងជួយបង្កើនសមត្ថភាពរបស់ប្រទេសក្នុងការទប់ទល់បញ្ហាប្រឈមពីខាងក្រៅ។ ជាការពិត ចំនួនប្រទេសដែលបាននាំចូលអង្ករពីកម្ពុជាមានការកើនឡើងពីចំនួន ៣០ប្រទេស ពេលចាប់ផ្តើមគម្រោង ដល់ចំនួន ៧៩ប្រទេស គិតត្រឹមខែកក្កដា ឆ្នាំ២០១៤ តួលេខនេះបានឆ្លុះបញ្ចាំងនូវលទ្ធផលសម្រេចបានការធ្វើពិពិធកម្មទីផ្សាររបស់កម្ពុជា។

[3] WT/TPR/G/253, Page 7, para. 16, November 2011

ចំពោះភាគីរាជរដ្ឋាភិបាល ការពន្យារពេលការរៀបចំសមាសភាគមុខងារវាយតម្លៃ អាចនឹងធ្វើឱ្យប៉ះពាល់ដល់រាជរដ្ឋាភិបាលដែលនឹងទទួលបានប្រយោជន៍ពីការទទួលបានចំណេះដឹង និងជំនាញបច្ចេកទេសពីការងារគម្រោងនេះ។ DICO/ MoC គួរតែខិតខំឱ្យបានខ្លាំងក្លាក្នុងអំឡុងពេលដែលនៅសេសសល់របស់គម្រោងដើម្បីដោះស្រាយបញ្ហាពន្យារពេលនេះ។

ហេតុដូចនេះ គម្រោងនេះ **មិនអាចទទួលយកបាន** តាមរយៈនិរន្តភាពរបស់គម្រោងឡើយ ប្រសិនបើសកម្មភាពចំបងមិនត្រូវបានអនុវត្ត គឺការបង្កើតគណកម្មការសូត្រកម្ពុជា និងការពង្រឹងសហព័ន្ធអង្ករកម្ពុជា និងប្រតិបត្តិការពេញលេញនៃមន្ត្រីក្រុមស្នូលក្នុងការអនុវត្តន៍សមាសភាគរងនៃគម្រោង CEDEP I ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

គម្រោង CEDEP I មានភាពជាវិជ្ជមានយោងតាមលទ្ធផលដែលសម្រេចបាននៅផ្នែកទីផ្សារនាំចេញ និងការអភិវឌ្ឍន៍ផលិតផល របស់សមាសភាគទាំងពីរ អង្ករ និងសូត្រ។ លទ្ធផលនេះបានបង្ហាញពីសក្តានុពលភាព វិស័យទាំងពីរនេះក្នុងបរិយាសកាសដ៏លំបាកនៅកម្រិតជាតិដោយមានការចំណាយខ្ពស់ក្នុងការធ្វើពាណិជ្ជកម្ម និងមានការប្រកួតប្រជែងខ្លាំងពីបណ្តាប្រទេសជិតខាងនៅកម្រិតអន្តរជាតិ។ លទ្ធផលដែលសម្រេចបាន គួរទទួលបានការសរសើរ និងមានចេរភាពនៅពាក់កណ្តាលដំណាក់កាលទី២នៃគម្រោង។ ប៉ុន្តែវាអាចកើតឡើងបានលុះត្រាតែមានកិច្ចប្រឹងប្រែងក្នុងការបង្កើតស្ថាប័ន ដោយមានគម្រោងផែនការច្បាស់លាស់ ក្នុងការរួមដំណើរជាមួយអ្នកនាំចេញ ក្នុងយុទ្ធសាស្រ្តនាំចេញរបស់ពួកគេជួយសម្របសម្រួល និងយុទ្ធសាស្រ្តណែនាំនៅកម្រិតវិស័យទាំងមូល។

ឧបសគ្គដែលប្រឈមនៅក្នុងសេដ្ឋកិច្ចកម្ពុជាចំពោះវិស័យអង្ករ និងសូត្រគួរត្រូវបានកំណត់នៅក្នុងយុទ្ធសាស្រ្តទីផ្សារដើម្បីដាក់ចេញអនុវត្ត។ ជាការពិត ការប្រៀបធៀបគុណសម្បត្តិកម្ពុជាតាមនិយមន័យ **<u>ទីផ្សារពិសេស និងទំហំតូច</u>** គឺផ្អែកលើ **<u>គុណភាព និងភាពស៊ីគ្នា</u>** នៃការនាំចេញផលិតផល (**<u>អង្ករក្រអូប និងសូត្រប្រណិត</u>**)។ នេះគឺជាភាពខ្លាំងរបស់កម្ពុជាលើវិស័យសូត្រ និងអង្ករដូច្នេះគម្រោងនេះនឹងអាចជួយចូលរួមចំណែកក្នុងគោលដៅនេះ។ សមាសភាគទី៣ ស្តីពីមុខងារវាយតម្លៃគួរផ្តល់យុទ្ធសាស្រ្តគាំទ្រចាំបាច់ ដោយជំរុញនិងបញ្ជ្រាបលទ្ធផល រវាងរាជរដ្ឋាភិបាល និងសមាសភាគទី៣ តាមរយៈមន្ត្រីក្រុមស្នូល ដោយធ្វើការវាយតម្លៃពីវឌ្ឍនភាពដែលសម្រេចបាន។

សរុបសេចក្តីមក MTE ស្នើឱ្យបង្កើនពេលវេលារយៈពេល ១ឆ្នាំ គ្រប់សមាសភាគទាំងអស់ដើម្បីបំពេញបានលទ្ធផលដែលរំពឹងទុក និងមានភាពសមស្របលើកិច្ចប្រតិបត្តិការនិងមូលនិធិដែលអាចប្រើប្រាស់បាន។

គ្រប់សមាសភាគទាំងអស់ត្រូវធ្វើការប៉ាន់ប្រមាណមូលនិធិដែលនឹងត្រូវបង្កើនក្នុងអំឡុងពេលស្នើនេះ និងលទ្ធផលដែលសម្រេចបានបន្ទាប់ពីការវាយតម្លៃពាក់កណ្តាលគម្រោង។

ចំពោះករណី ITC ការបង្កើនពេលវេលារបស់គម្រោងនឹងតម្រូវឱ្យមានការបង្កើនធនធានសម្របសម្រួលសំរាប់ ITC និង MoC ក្នុងការគ្រប់គ្រងគម្រោង លទ្ធផលទី៣ លើសពីខែកញ្ញា ឆ្នាំ២០១៥ និងប្រភពមូលនិធិបន្ថែមដែលត្រូវការ។ ដូច្នេះ យើងអាចទាញយកចំណុចសំខាន់មកបង្ហាញគឺ **គម្រោងគួរត្រូវបានបង្កើនពេលវេលា ដូចនេះទាមទារឱ្យមានតម្រូវការបន្ថែមលើការគ្រប់គ្រង/សម្របសម្រួលថវិកា**។ កិច្ចប្រតិបត្តិការគម្រោងគួរត្រូវកម្រិតត្រឹមលទ្ធផលតែមួយប៉ុណ្ណោះ (លទ្ធផលទី៣) បន្ទាប់ពីខែកញ្ញា ឆ្នាំ២០១៥ ខណៈពេលដែលការគាំទ្រដោយផ្ទាល់ដល់អាជីវកម្ម សូត្រនិងអ្នកតម្បាញមិនអាចបន្តបាន បន្ទាប់ពី

ធនធានហិរញ្ញវត្ថុសម្រាប់លទ្ធផលទី១ និងទី២ បានអស់។ ការគាំទ្រក្រុមហ៊ុន និងអ្នកតម្បាញគឺតម្រូវឱ្យមានប្រភពមូលនិធិបន្ថែម។

ខាងក្រោមនេះជាតារាងអនុសាសន៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ។ អនុសាសន៍ទាំងនេះទាញចេញមកពីការវិភាគលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលគម្រោង។ អនុសាសន៍នេះមានគោលបំណងធានាបានថាគោលដៅ និងផលប៉ះពាល់ របស់ CEDEP I នឹងអាចសម្រេចបាន ពេលបញ្ចប់គម្រោង។ អនុសាសន៍នេះក៏បានបង្ហាញពីតម្រូវការ និងការស្នើសុំធ្វើឡើយដោយភាគីពាក់ព័ន្ធក្នុងអំឡុងពេលវាយតម្លៃពាក់កណ្តាលគម្រោង មានដូចជា MIE ភ្នាក់ងាររដ្ឋា-ភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកទទួលផលពីគម្រោង CEDEP I។

| **លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ** | **អនុសាសន៍** |
|---|---|
| **ទំនាក់ទំនង** | បន្តជាអតិបរមា និងប្រក្រតីភាព ចំពោះច្បាប់ដែលមានស្រាប់ និងបង្កើតគម្រោងផែនការថ្មី បទបញ្ញត្តិ និងគោលនយោបាយ។<br>*អង្គភាពទទួលខុសត្រូវ៖ CEDEP I MIEs*<br>ធ្វើការពិចារណាណែនាំសកម្មភាពការងារដែលមានទំនាក់ទំនងជាមួយកំណើនការនាំចេញតាមរយៈការធ្វើពិពិធកម្ម ដោយរួមបញ្ចូលការអភិវឌ្ឍន៍ផលិតផល និងសេវាដែលត្រូវបានកំណត់ថាជាវិស័យអាទិភាព (១៩ ផលិតផល) ដោយរាជរដ្ឋាភិបាលកម្ពុជា។ ហេតុនេះ គម្រោងនឹងមានឱកាសកើនឡើងក្នុងការទទួលបានមូលនិធិពីដៃគូអភិវឌ្ឍន៍ ដែលជំរុញឱ្យមានការសម្របសម្រួល និងការប្រមូលកម្លាំងជាមួយ Trade SWAp និង AfT។<br>*អង្គភាពទទួលខុសត្រូវ៖ CEDEP I MIEs*<br>បង្កើនការយកចិត្តទុកឱ្យបានច្រើនចំពោះបរិបទជាតិ និងអន្តរជាតិ ចំពោះលទ្ធផលដែលសម្រេចបាន ដើម្បីឆ្លុះបញ្ចាំងចំណាយពាណិជ្ជកម្ម (ចំណាយផលិតកម្ម និងចំណាយនាំចេញ) និងរនាំងបច្ចេកទេសពាណិជ្ជកម្ម ដោយដាក់បញ្ចូលបញ្ហា និងការប្រកួតប្រជែងពាក់ព័ន្ធទៅនឹងចំណាយ ពន្ធគយ និងសមាហរណកម្មបទបញ្ញត្តិឱ្យមានភាពសមស្របគ្នាក្នុងតំបន់។<br>*អង្គភាពទទួលខុសត្រូវ៖ CEDEP I MIEs*<br>កែតម្រូវគោលដៅសូចនាករ និងសូចនាករសំខាន់ៗនៃកិច្ចប្រតិបត្តិការ (KPIs) នៃទីផ្សារពិសេសដោយផ្តោតទៅលើគុណភាព និងភាពស៊ីគ្នា ធៀបជាមួយទីផ្សារធំ ដែលប្រទេសកម្ពុជាមិនអាចផ្គត់ផ្គង់។<br>*អង្គភាពទទួលខុសត្រូវ៖ CEDEP I MIEs* |

| | |
|---|---|
| **ប្រសិទ្ធផល** | គឺជារឿងសំខាន់ដែលអនុក្រិត្យស្តីពីតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់គណកម្មការសូត្រថ្នាក់ជាតិ ត្រូវបានអនុម័ត និងយកមកអនុវត្តឱ្យបានឆាប់រហ័ស។ តម្រូវឱ្យមានការតស៊ូមតិពាក់ព័ន្ធនឹងការអនុវត្តន៍លទ្ធផលទី៣ នៃសមាសភាគសូត្រប្រណិត ដោយការបង្កើតគណកម្មការសូត្រថ្នាក់ជាតិ។<br>*អង្គភាពទទួលខុសត្រូវ៖ **រាជរដ្ឋាភិបាល និង ITC***<br>ពង្រឹងសមត្ថភាព តាមដាន និងវាយតម្លៃ របស់ DICO ដែលទទួលខុសត្រូវគម្រោង CEDEP I ដើម្បីទទួលបាននូវទិន្នផលដែលរំពឹងទុក។<br>*អង្គភាពទទួលខុសត្រូវ៖ DICO*<br>ផ្សព្វផ្សាយការរកឃើញសំខាន់ៗ នៃការវាយតម្លៃពាក់កណ្តាលគម្រោង បន្ទាប់ពីការអនុម័តរបស់ EIF ES និង MIEs។<br>*អង្គភាពទទួលខុសត្រូវ៖ DICO*<br>ធ្វើបច្ចុប្បន្នភាព ផែនការលម្អិត និងតារាងពេលវេលានៃការអនុវត្តន៍គម្រោងឲ្យសមស្របទៅនឹងស្ថានការណ៍ថ្មីរបស់សមាសភាគទាំងបី។<br>*អង្គភាពទទួលខុសត្រូវ៖ **MIEs មន្ត្រីទំនាក់ទំនង និងវិស័យឯកជន***<br>រៀបចំកិច្ចប្រជុំរវាងមន្ត្រីក្រុមស្នូល និង MIEs ដើម្បីផ្តល់ព័ត៌មានពីសមាជិកមន្ត្រីក្រុមស្នូល និងការផ្លាស់ប្តូរអាណត្តិ និងសកម្មភាព តាមរយៈការចុះហត្ថលេខា លើការកែប្រែ MoU និងកំណត់ផែនការសកម្មភាពដែលត្រូវអនុវត្តដោយ MIEs និងមន្ត្រីក្រុមស្នូលរួមគ្នា។<br>*អង្គភាពទទួលខុសត្រូវ៖ **CEDEP I MIEs និងមន្ត្រីទំនាក់ទំនង***<br>ពង្រឹងការសម្របសម្រួលដោយបង្កើតបញ្ញត្តិក្នុងកិច្ចប្រជុំរបស់ MIEs ដើម្បីពិភាក្សាវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាដែលលេចឡើងអំឡុងពេលអនុវត្តគម្រោង។<br>*អង្គភាពទទួលខុសត្រូវ៖ CEDEP I MIEs*<br>បង្ហាញជម្រើសផ្សេងៗ និងឱកាសផ្សេងៗ ដល់ IFC ដើម្បីចុះ MoU ជាមួយ CRF។<br>*អង្គភាពទទួលខុសត្រូវ៖ IFC និង CRF*<br>បង្កើនប្រសិទ្ធិផលការប្រើប្រាស់មូលនិធិ របស់សមាសភាគអង្ករ និងសូត្រប្រណិតដើម្បីសម្រេចបានការងារពេញលេញគ្រប់សកម្មភាពទាំងអស់ ជាមួយមូលនិធិដែលនៅសល់ក្នុងពេលបច្ចុប្បន្ន (លើកលែងការបង្កើនពេលវេលា)។ ផ្អែកលើបរិបទនៃអត្រាចំណាយខ្ពស់ (៨៥%) របស់ ITC ត្រឹមខែកក្កដាឆ្នាំ |

| | |
|---|---|
| | ២០១៤ ហើយការបិទបញ្ចប់គម្រោងរបស់ EU-SME ដោយ IFC គឺនៅដំណាច់ឆ្នាំ២០១៤។<br><br>*អង្គភាពទទួលខុសត្រូវ៖ **IFC និង ITC*** |
| **ប្រសិទ្ធភាព** | បង្កើតយុទ្ធសាស្ត្រតាមដានការចរចាកិច្ចព្រមព្រៀងអង្ករ ដោយផ្តល់បន្ថែមបច្ចេកទេសដាក់បញ្ចូលក្នុងទីផ្សារ ជាពិសេសចំពោះទីផ្សារអាស៊ី។ យុទ្ធសាស្ត្រនេះ គួរដាក់បញ្ចូលនៅកំណត់ត្រាបច្ចេកទេសស្តីពីទីផ្សារជាក់លាក់ណាមួយ និងសេចក្តីណែនាំពាណិជ្ជកម្មដើម្បីជួយដល់អ្នកនាំចេញអង្ករធ្វើការបញ្ចប់កិច្ចព្រមព្រៀង[4]។<br><br>*អង្គភាពទទួលខុសត្រូវ៖ IFC*<br><br>សម្របសម្រួលកិច្ចព្រមព្រៀងក្នុងការចរចាអំពីកូតា ឬប្រើប្រាស់កូតាដែលបានបែងចែកដល់ប្រទេសកម្ពុជា (ឧ. កូតានាំចេញរបស់ប្រទេសចិន) ឱ្យបានពេញលេញដើម្បីកាត់បន្ថយគំនាបក្នុងការប្រកួតប្រជែងជាមួយទីផ្សារវៀតណាម និងទីផ្សារថៃ។<br><br>*អង្គភាពទទួលខុសត្រូវ៖ **IFC និង ITC***<br><br>ពង្រឹងកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងវិស័យឯកជនតាមរយៈក្រុមការងារ G-PS ឱ្យបានញឹកញាប់។ ផែនការសកម្មភាពគួរត្រូវបានរៀបចំសម្រាប់ក្រុមការងារនីមួយៗយកមកអនុវត្តនូវលទ្ធផលដែលសម្រេចបានរបស់ CEDEP I ដើម្បីទទួលបានប្រសិទ្ធភាព។<br><br>*អង្គភាពទទួលខុសត្រូវ៖ **រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន***<br><br>ជំរុញការគាំទ្រម៉ាកផលិតផលកម្ពុជា។<br><br>*អង្គភាពទទួលខុសត្រូវ៖ **រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន***<br><br>សហការណ៍ជាមួយភាគីពាក់ព័ន្ធរាជរដ្ឋាភិបាល និងជួយកំណត់នូវវិធី-សាស្ត្រអនុវត្តដ៏ល្អមួយ ក្នុងការរៀបចំគោលនយោបាយតាមរយៈការតស៊ូមតិដើម្បីទទួលបានរចនាសម្ព័ន្ធរបស់ស្ថាប័ន។<br><br>*អង្គភាពទទួលខុសត្រូវ៖ **រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន***<br><br>រៀបចំរចនាសម្ព័ន្ធរបស់វិស័យឯកជនដើម្បីការពារផលប្រយោជន៍របស់កម្ពុជា (ការពារផលប្រយោជន៍រួមនៃប្រាក់កម្ចីធនាគារ កូតាពាណិជ្ជកម្ម ។ល។) និងបង្កើនការប្រកួតប្រជែង។ ការងារនេះគួរតែវិស័យឯកជនជាអ្នកអនុវត្ត ដើម្បីទទួលបានការចរចាល្អប្រសើរស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងប្រាក់កម្ចី។<br><br>*អង្គភាពទទួលខុសត្រូវ៖ **វិស័យឯកជន*** |

[4] ត្រូវបានស្នើឡើងដោយអ្នកនាំចេញអង្ករអំឡុងពេលវាយតម្លៃពាក់កណ្តាលគម្រោង

| | |
|---|---|
| **សក្តានុពលនៃផលប៉ះពាល់** | បន្តការចរចាដើម្បីឱ្យមានការរួចពន្ធនាំចូល ចំពោះការនាំចូលសរសៃអំបោះសូត្រ ដែល ៩៩% ត្រូវបាននាំចូលពីប្រទេសវៀតណាម។<br>*អង្គភាពទទួលខុសត្រូវ៖* ***រាជរដ្ឋាភិបាលកម្ពុជា ITC និងវិស័យឯកជន***<br>កំណត់សូចនាករសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស និង KPIs ដើម្បីធ្វើការវាស់វែងពីផលប៉ះពាល់របស់គម្រោងក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើតការងារ និងភាពងាយរងគ្រោះសេដ្ឋកិច្ចរបស់កម្ពុជា[5]។<br>*អង្គភាពទទួលខុសត្រូវ៖ MIEs*<br>បង្កើនចំនួនអ្នកទទួលផល (ទោះបីជាចំនួននេះច្រើនជាងចំនួនដែលបានកំណត់នៅក្នុងឯកសារគម្រោង (ពី៨-១២)) ក្នុងសមាសភាគសូត្រប្រណិតដើម្បីឲ្យបានផលដល់វិស័យទាំងមូល។ សកម្មភាពមួយចំនួន ត្រូវបានអនុវត្តដោយ ITC ដើម្បីទទួលបានកម្មករផ្នែកសូត្របន្ថែមទៀត ទោះបីប្រឈមនឹងហានិភ័យបាត់បង់គោលដៅប្រសិន បើវិសាលភាពនៃអន្តរាគមន៍របស់គម្រោងត្រូវបានពង្រីកឡើង បង្កឱ្យមានឧបសគ្គក្នុងការផ្តល់មូលនិធិ។<br>*អង្គភាពទទួលខុសត្រូវ៖ ITC*<br>ពង្រីកវិសាលភាពសកម្មភាពរបស់សមាសភាគសូត្រដើម្បីដោះស្រាយបញ្ហាមួយចំនួនដូចជាការទទួលបាននូវឥណទាន និងសមត្ថភាពផ្គត់ផ្គង់។<br>*អង្គភាពទទួលខុសត្រូវ៖ ITC*<br>ធានាលើការផ្លាស់ប្តូរដោយរលូនពីលក្ខណៈមិនផ្លូវការឆ្ពោះទៅកាន់ផ្លូវការក្នុងវិស័យសូត្រដើម្បីជំរុញខ្សែសង្វាក់តម្លៃរបស់សូត្រ និងការពារបុគ្គលិក និងពាណិជ្ជកម្មផ្នែកសូត្រ។<br>*អង្គភាពទទួលខុសត្រូវ៖* ***រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពី ITC*** |
| **និរន្តភាព** | ខិតខំអភិវឌ្ឍន៍ និងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសម្រាប់រយៈពេលវែងដើម្បីចេរភាពកំណើនសេដ្ឋកិច្ច និងបំពេញបាននូវសក្តានុពលនៃកំណើនទីផ្សារ ដូចជាអង្ករ និងសូត្រ។<br>*អង្គភាពទទួលខុសត្រូវ៖* ***រាជរដ្ឋាភិបាលកម្ពុជា***<br>គាំទ្រដល់ការបង្កើតគណកម្មការសូត្រថ្នាក់ជាតិ ឱ្យបានមុនដំណាច់ឆ្នាំ២០១៤ ប្រសិនបើអាចធ្វើបាន ដើម្បីចៀសវាងការពន្យារពេលកាន់តែយូរដល់ការអនុវត្តន៍លទ្ធផលទី៣ នៃសមាសភាគសូត្រ។<br>*អង្គភាពទទួលខុសត្រូវ៖* ***រាជរដ្ឋាភិបាលកម្ពុជា ITC*** |

[5] ពេលបញ្ចប់គម្រោងការស្ទង់មតិពីផលប៉ះពាល់ស្ថិតនៅក្នុងផ្នែកមួយនៃផែនការការងាររបស់សមាសភាគសូត្រប្រណិត និងត្រូវអនុវត្តនៅឆ្នាំ ២០១៥។ ITC ត្រូវប្រាកដថាអាំងឌីកាទ័រនៃការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានដាក់បញ្ចូលទៅក្នុងការស្ទង់មតិ។

| | |
|---|---|
| | ពង្រឹងសហព័ន្ធស្រូវអង្ករកម្ពុជា តាមរយៈការកសាងសមត្ថភាពដើម្បីធ្វើប្រតិបត្តិការបានឆាប់រហ័សទៅតាមអាណត្តិ និងមុខងាររបស់សហព័ន្ធ។<br>*អង្គភាពទទួលខុសត្រូវ៖ **រាជរដ្ឋាភិបាលកម្ពុជា IFC និង វិស័យឯកជន***<br>ធានាស្ថេរភាពនៃលទ្ធផលល្អប្រសើររបស់សមាសភាគអង្ករ តាមរយៈការសម្របសម្រួល រវាង IFC និង CRF ក្នុងការអនុវត្តន៍ផែនការលម្អិតដើម្បីធានាបាននូវការផ្លាស់ប្តូរដោយរលូនពេលផ្ទេរការទទួលខុសត្រូវ។<br>*អង្គភាពទទួលខុសត្រូវ៖ **IFC និង CRF***<br>បង្កើនពេលវេលា និងកិច្ចប្រឹងប្រែងលើមុខងារវាយតម្លៃជាមួយនិង DICO ដើម្បីដោះស្រាយបញ្ហាពន្យារពេល ក្នុងការបញ្រ្ជាប និងចែកចាយជំនាញឯកទេស និងចំណេះដឹងដែលទទួលបានចាប់តាំងពីពេលចាប់ផ្តើមគម្រោង នៅក្នុងសមាសភាគអង្ករ និងសូត្រ។<br>*អង្គភាពទទួលខុសត្រូវ៖ **DICO និងមន្ត្រីក្រុមស្នូល***<br>ធានានិរន្តភាព ដោយចាប់ផ្តើមពីការសាងផែនការសម្រាប់ចំណាយ និងតាមដានគម្រោងក្នុងវិស័យអង្ករ និងសូត្រ[6] ត្រូវបានយកមកអនុវត្តពេលបិទបញ្ចប់គម្រោង EU/RSSP នាបំណាច់ឆ្នាំ២០១៤ និង TDSP នាបំណាច់ឆ្នាំ២០១៦ និងការអនុវត្តន៍តាមតារាងពេលវេលារបស់ CTIS ២០១៤-២០១៨ និងផែនទីបង្ហាញផ្លូវរបស់ Trade SWAp ។<br>*អង្គភាពទទួលខុសត្រូវ៖ **MIEs*** |

[6] ITC បានធ្វើផែនការ និងបង្ហាញពីមធ្យោបាយក្នុងការផ្តល់ការបន្តគាំទ្រដល់ក្រុមហ៊ុន អ្នកតម្បាញ ពេលបញ្ចប់គម្រោង។ ដោយរួមបញ្ចូលដូចខាងក្រោម៖

- គាំទ្រដល់ក្រុមហ៊ុនកម្ពុជា និងអ្នកតម្បាញធ្វើការអភិវឌ្ឍន៍ជំនាញរបស់គេ និង niche ethical fashion market ដែលជាផ្នែកមួយនៃកម្មវិធីជាសកល Ethincal Fashion របស់ ITC
- គាំទ្រដល់ស្ត្រីកម្ពុជា ក្នុងការដាំសូត្រ ច្នៃម៉ូត និងតម្បាញដើម្បីអភិវឌ្ឍន៍ផលិតផល និងលក់ចេញជាអន្តរជាតិ ដែលជាផ្នែកមួយនៃកម្មវិធី Women Trade Programme របស់ ITC
- គម្រោងនេះក៏ស្ថិតក្នុងដំណើរការភាពជាដៃគូជាមួយសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) ដើម្បីលើកទឹកចិត្ត និងគាំទ្រដល់កំណើនអ្នកជំនួញជាស្ត្រីលើវិស័យសូត្រក្នុងប្រទេសកម្ពុជា ក្នុងការទទួលបានការគាំទ្រជាសក្តានុពលពីសមាគម ដើម្បីធានាបានស្ថេរភាពចំពោះលទ្ធផលទាំងឡាយ និងការគាំទ្រខ្លះដែលផ្តល់ប្រយោជន៍ដល់សហគ្រិនស្ត្រី ជាពេលបញ្ចប់គម្រោង។